មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៦-១១-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៨៧ ស្តីពី ការតែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ ចំនួន ០២ រូប ៩១០០

២៤-១១-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៩៣ ស្តីពី ការតែងតាំងលោកស្រី Florence Mumba (ជនជាតិសំប៊ី) ជាចៅក្រមអន្តរជាតិ និង លោក Phillip Rapoza (ជនជាតិអាមេរិក) ជាចៅក្រមបម្រុងអន្តរជាតិ នៅអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៩១០១

២៤-១១-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៩៤ ស្តីពី ការតាំងស៊ប់ក្នុងក្របខណ្ឌអង្គចៅក្រម ចំពោះចៅក្រមកម្មសិក្សា-ព្រះរាជអាជ្ញារងកម្មសិក្សា ចំនួន ៥៥ នាក់ ជាចៅក្រម និង ព្រះរាជអាជ្ញារង និងត្រូវចាត់ឱ្យបំរើការងារតាមអង្គភាព និងសាលាជំរះក្តីនានា ៩១០២

២៤-១១-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៩៥ ស្តីពី ការផ្ទេរតំណែង លោក **លូ ស៊ីសម្បត្តិ** ប្រធានសាលាដំបូងខេត្តរតនគិរី ទៅជាចៅក្រមសាលាដំបូង ខេត្តមណ្ឌលគិរី និង តែងតាំងលោក **សួស ឡា** អនុប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ ទៅជាប្រធានសាលាដំបូងខេត្តរតនគិរី ៩១០៦

២៤-១១-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៩៦ ស្តីពី ការផ្ទេរតំណែង លោក **ម៉េង គូនី** ចៅក្រមសាលាដំបូង ខេត្តមណ្ឌលគិរី ឱ្យមកបំរើការជាចៅក្រម សាលាដំបូងរាជធានីភ្នំពេញ ៩១០៧

២៤-១១-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៩៧ ស្តីពី ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរដោយគ្មានបៀវត្ស រយពេល ០១ ឆ្នាំ ចំពោះលោកស្រី **ស្រ៊ុន ឈន់ចលក្ខណ៍** និង លោក **កេខ សុម៉ារិទ្ធ** ចៅក្រមសាលាដំបូង ខេត្តកណ្តាល ៩១០៨

២៤-១១-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៩៨ ស្តីពី ការលុបឈ្មោះលោក **អ៊ុខ សារុន** ចៅក្រមសាលាឧទ្ធរណ៍ និង លោក **គ្រី សុខអ៊ី** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចេញពីក្របខណ្ឌអង្គចៅក្រម ដោយមរណភាព ៩១០៩

២៤-១១-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៩៩ ស្តីពី ការតែងតាំងឯកឧត្តម **ខៀវ ច័ន្ទម៉ុនធឿន** ជាអនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ជំនួសឯកឧត្តម **ម៉ែន គួន** ដែលត្រូវបានទទួលភារកិច្ចថ្មី ៩១១០

២៨-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/១០០០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ មន្ត្រីអនុវត្តគម្រោង ចំនួន ០៥ រូប ៩១១១

២៨-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/១០០១ ស្តីពី ការតែងតាំងឯកឧត្តម **អ៊ួច ទិបុល** ជាអនុរដ្ឋលេខាធិការនៃក្រសួងធម្មការ និង សាសនា ៩១១២

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

១៦-១១-២០១២-អនុក្រឹត្យលេខ ២០៩ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៥.៨៥១,៧៦ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ទំហំ ២.៤៧៩,៨៨ ហិកតា និង ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន (គីម ជាធួន គ្រុប ខូ អិលធីឌី ឆាយណាប្រេដខស ខេមបូឌាហ្គ្រីនឈ័យ ខេមបូឌា លីមីធីត និង សីលាដាម៉ិច ខូ អិលធីឌី) ទំហំ ៣.៣៧១,៨៦ ហិកតា និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្ម ផ្តល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១៩៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែងលើដីទំហំ ៥.៣២៣,២៨ ហិកតា និង ទំហំ ៥២៨,៤៦ ហិកតា រក្សាទុក សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នៅក្រុងព្រះវិហារ ស្រុករវៀង និង ស្រុកគូលែន ខេត្តព្រះវិហារ ៩១១៣

២៦-១១-២០១២-អនុក្រឹត្យលេខ ២១០ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩៨៤,៣៨ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ៩១១៩

២៦-១១-២០១២-អនុក្រឹត្យលេខ ២១១ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩៨០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ៩១២១

២៦-១១-២០១២-អនុក្រឹត្យលេខ ២១២ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១៣,៧៦០ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ពីព្រៃសម្បទានយូរីសាគរ ពីដីសម្បទានព្រៃឫស្សីក្រុមហ៊ុន ភាពីម៉ិក ពីដែនជម្រកសត្វព្រៃសំកុស និង ពីដីសហគមន៍ព្រៃឈើព្រៃត្រឡាច និង ភ្នំរូង ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១២,៥១៣ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.២១៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង និង ដីភ្នំ ទំហំ ១.២៤៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុករុក្ខគីរី និង ស្រុកសំឡូត ខេត្តបាត់ដំបង ៩១២៣

២៣-១០-២០១២-អនុក្រឹត្យលេខ **១៩២៧** ដល់អនុក្រឹត្យលេខ **១៩៧៦** អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៩១៧៧

២_សេចក្ដីសម្រេច

១៤-១១-២០១២-សេចក្ដីសម្រេចលេខ ៤៥ សសរ ស្ដីពី ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីពិភាក្សាជាមួយប្រតិភូគណៈកម្មាធិការកិច្ចការព្រំដែនវៀតណាម អំពីបញ្ហាមួយចំនួននៅតាមច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម ៩១៧៨

២២-១១-២០១២-សេចក្ដីសម្រេចលេខ ៤៦ សសរ ស្ដីពី ការបង្កើតគណៈបញ្ជាការដឹកនាំត្រួតពិនិត្យ និង លុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក-ផ្លូវទឹក ៩១៨១

III_ការងារបណ្ដាក្រសួង

១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

០២-៧-២០១២ -ប្រកាសលេខ ៣៦០ ប្រក.កសក ស្ដីពី ការគ្រប់គ្រង និង ការដាក់ឱ្យប្រើប្រាស់ស្លាកលេខសម្គាល់សត្វចតុប្បាទ ៩១៨៤

២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៦-១០-២០១២-ប្រកាសលេខ ១០៧០ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន តាកែវ ស៊ូ (ខេមបូឌា) បង្កើតរោងចក្រ ផលិតស្បែកជើង ៩១៩១

២៦-១០-២០១២-ប្រកាសលេខ ១០៧១ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យូ នី ប្រូស (ខេមបូឌា) អេនធើប្រាយ បង្កើតរោងចក្រ ផលិតតង់គ្រប់ប្រភេទ ៩១៩៥

០១-១១-២០១២-ប្រកាសលេខ ១០៩៩ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីខេ ហ្វោនជ្រាយ បង្កើតរោងចក្រ ផលិតបរិក្ខាបន្ទុំគ្រឿងចក្រ-គ្រឿងម៉ាស៊ីន និង គ្រឿងបរិក្ខារបន្ទុំផ្សេងៗ ៩១៩៩

០៦-១១-២០១២-ប្រកាសលេខ ១១០៥ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អហ្គែនិក អេហ្គ្រីខលឆឺរ៉ល ប្រដាក់ (ខេមបូឌា) បង្កើតរោងចក្រ ផលិតម្សៅដំឡូងមី-ម្សៅដំឡូងជ្វា ៩២០៣

៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៨-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៦៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជាតិ អគិទឡន៍ អ៊ិនវេស មេន គ្រុប** ៩២០៧

១៨-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៦៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជីង ស៊ីន ត័ង យិ ខៃ ហ្វា** ៩២០៩

១៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៦៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ញូ ហូង ជាត ប្លាស្ទិក ព្រីនធីង ៩២១១

១៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៦៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ច័ន អ៊ែកសេស មេឌា ខូ អិលធីឌី ៩២១៣

១៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៧១ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី ៩២១៥

១៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៧៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឆេមស្ការ អ៊ិនធើណេសិនណល គ្រឌីង ៩២១៦

១៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៧៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហាយ ថេត ប៊ីហ្សនេស យេផេន ៩២១៨

១៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៧៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ប្រាក់ ម៉ារ៉ា អតិចឡន៍ ដំណាំកសិឧស្សាហកម្ម ៩២២០

១៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៧៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ្គោលដេន អ៊ែគល ខេម ៩២២២

ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ ចំនួន ០២ រូប :

១- ឯកឧត្តម **ហេង អៀម** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម **គីម សំអាត** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ៩៧០ច.ល

៣ រកត.១២១១.៩៩៧

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរង[illegible]រាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២

[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រមលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២

ត្រាស់បង្គាប់

មាត្រា១៖ តែងតាំងៈ

១-លោកស្រី Florence Mumba (ជនជាតិសំប៊ី) ជាចៅក្រមអន្តរជាតិនៅអង្គជំនុំជម្រះតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជំនួសចៅក្រម Motoo Noguchi (ជនជាតិជប៉ុន) ដែលបានលាឈប់ ។

២-លោក Phillip Rapoza (ជនជាតិអាមេរិក) ជាចៅក្រមបម្រុងអន្តរជាតិ នៅអង្គជំនុំជម្រះតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

មាត្រា២៖ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣៖ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.រស. ១២១១.១០០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២

លេខៈ ៩៦៣ ច.ល
[illegible]
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែវិច្ឆិកា ឆ្នាំ២០១២
អគ្គ[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៩៤

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដីនៃរដ្ឋកម្ពុជា
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២

ត្រាស់បង្គាប់

មាត្រា១: តាំងស៊ប់ក្នុងក្របខណ្ឌអង្គចៅក្រម ចំពោះចៅក្រមកម្មសិក្សា-ព្រះរាជអាជ្ញារងកម្មសិក្សា ចំនួន ៥៥ នាក់ ជាចៅក្រម និងព្រះរាជអាជ្ញារង និងត្រូវចាត់ឲ្យបំពេញការងារនៅតាមអង្គភាព និងសាលាជំរះក្ដីនានា :

ក-សាលាដំបូង-អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

១ - លោក **ជួន សុរាសី** ជាចៅក្រម

២ - លោក **គីម រ័ត្នណារិន** ជាចៅក្រម

៣ - កញ្ញា **ទ៉ា សត្ថា** ជាព្រះរាជអាជ្ញារង

៤ - លោក **លី សុផាណា** ជាព្រះរាជអាជ្ញារង

៥ - លោក **ហោ លីណា** ជាព្រះរាជអាជ្ញារង

ខ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកណ្ដាល

១ - លោក **នៃ ទិទឡ្យនៈ** ជាចៅក្រម

២ - លោក **សំម ឫទ្ធីវាសនា** ជាព្រះរាជអាជ្ញារង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

គ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពង់ចាម

១ - លោក **យុន សុណា** ជាចៅក្រម

២ - លោក **ប៉ុក សុវណ្ណមុនី** ជាចៅក្រម

៣ - លោក **ស៊ិន មុនី** ជាព្រះរាជអាជ្ញារង

ឃ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តបាត់ដំបង

១ - កញ្ញា **យិច ឈានណាទី** ជាចៅក្រម

២ - លោកស្រី **សុខ ទិសាល** ជាព្រះរាជអាជ្ញារង

ង-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តព្រៃវែង

១ - លោក **គី ម៉ានេវ៉ា** ជាចៅក្រម

២ - លោក **ឃ្លោក ពិសិដ្ឋ** ជាចៅក្រម

៣ - លោក **ឈើន សុផុន** ជាព្រះរាជអាជ្ញារង

ច-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តសៀមរាប

១ - លោក **គួយ សៅ** ជាចៅក្រម

២ - លោក **លឹម សុគន្ធារ៉ា** ជាចៅក្រម

៣ - កញ្ញា **ជុំ សទ្ធា** ជាចៅក្រម

៤ - លោក **ចែ សុខ** ជាចៅក្រម

៥ - លោក **សំ ប៊ុនពៅ** ជាចៅក្រម

៦ - លោក **សំរិទ្ធ សុខុន** ជាព្រះរាជអាជ្ញារង

៧ - លោក **ស្រ៊ា រតនៈ** ជាព្រះរាជអាជ្ញារង

៨ - កញ្ញា **ឌីម គឹមកល្យាណ** ជាព្រះរាជអាជ្ញារង

៩ - លោកស្រី **ឈួន សុភា** ជាព្រះរាជអាជ្ញារង

ឆ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តតាកែវ

១ - លោក **ឡុខ សិភា** ជាចៅក្រម

២ - លោក **ជ័យ រិទ្ធី** ជាព្រះរាជអាជ្ញារង

ជ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

១ - លោក **ជូ លឹមហ៊ាង** ជាចៅក្រម

២ - លោក **តូច ពុទ្ធារ៉ា** ជាចៅក្រម

៣ - លោក **នឹម ឬទ្ធី** ជាចៅក្រម

៤ - លោក **ឌុង រតនា** ជាព្រះរាជអាជ្ញារង

៥ - លោក **ស៊ឿ ឡុងឌី** ជាព្រះរាជអាជ្ញារង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ឈ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ

១ - លោក **ឡុយ ចាន់ត្រា** ជាចៅក្រម

២ - លោក **អ៊ី សាទិញ** ជាចៅក្រម

៣ - លោក **ថៃ គឹមមុនី** ជាចៅក្រម

៤ - លោក **មុយ សុភ័ក្ត្រ** ជាចៅក្រម

៥ - កញ្ញា **ឃិន សុគន្ធារី** ជាព្រះរាជអាជ្ញារង

៦ - លោកស្រី **កែវ សុគន្ធា** ជាព្រះរាជអាជ្ញារង

៧ - កញ្ញា **សុខ ឆវ័ន្ត** ជាព្រះរាជអាជ្ញារង និងបំពេញការងារជាព្រះរាជអាជ្ញារងនៅការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ញ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពត

១ - លោកស្រី **ឃី សុខទូច** ជាចៅក្រម

២ - លោក **ហុង សុគុណា ចន្ទ្រានា** ជាចៅក្រម

៣ - លោក **ទុប ឈុនសុខ** ជាចៅក្រម

៤ - លោក **ឃន ចាន់ធឿន** ជាចៅក្រម

៥ - លោក **ខៃ សម្ផស្ស** ជាព្រះរាជអាជ្ញារង

ដ-អយ្យការអមសាលាដំបូងខេត្តស្វាយរៀង

១ - លោក **ផាន់ រតនា** ជាព្រះរាជអាជ្ញារង

ឋ-សាលាដំបូងខេត្តកំពង់ឆ្នាំង

១ - លោក **សុភ ហេង** ជាចៅក្រម

ឌ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តពោធិសាត់

១ - លោក **ម៉ៅ ស៊ីណា** ជាចៅក្រម

២ - លោកស្រី **ឆេង ហាក់ចិង** ជាព្រះរាជអាជ្ញារង

ឍ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តក្រចេះ

១ - លោក **រស់ សាម៉ឺឌី** ជាចៅក្រម

២ - លោក **ចាន់ ឃុង** ជាចៅក្រម

៣ - លោក **ធុច បញ្ញាសន្តិភាព** ជាព្រះរាជអាជ្ញារង

ណ-សាលាដំបូងខេត្តព្រះសីហនុ

១ - លោក **អ៊ី យាង** ជាចៅក្រម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ឆ-សាលាដំបូងខេត្តកោះកុង

១ - លោក **សាំង សេរី** ជាចៅក្រម

ជ-សាលាដំបូងខេត្តស្ទឹងត្រែង

១ - លោក **គង់ ភូមិន្ទ** ជាចៅក្រម

ឈ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី

១ - លោក **ស៊ុយ សុភា** ជាចៅក្រម

២ - លោក **ជា សុវណ្ណថេត** ជាព្រះរាជអាជ្ញារង

មាត្រា២: ចៅក្រម-ព្រះរាជអាជ្ញារងទាំង ៥៥នាក់ ខាងលើ មានសិទ្ធិទទួលប្រាក់បៀវត្ស មូលដ្ឋាន និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត តាមច្បាប់បានកំណត់ ។ សិទ្ធិទទួលប្រាក់ ឧបត្ថម្ភផ្សេងៗ សិទ្ធិឡើងឋានន្តរសក្តិ ឬឡើងថ្នាក់ ត្រូវបានគិតចាប់ពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ តទៅ ។

មាត្រា៣: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៤: ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៥: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត/១២១១/១០០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១២

លេខ: ៩៦៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ២០១២

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សូម សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រមលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២

ត្រាស់បង្គាប់

មាត្រា១: ត្រូវបាន:

- ផ្ទេរមុខតំណែង លោក **លុ ស៊ីសម្បត្តិ** ប្រធានសាលាដំបូងខេត្តរតនគិរី ទៅជាចៅក្រមសាលាដំបូងខេត្តមណ្ឌលគិរី ។
- តែងតាំងលោក **សួស ឡា** អនុប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ ទៅជាប្រធានសាលាដំបូងខេត្តរតនគិរី ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ការល.១២១១.១០០៥

លេខ: ៩៦៥ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

សយ សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២

ត្រាស់បង្គាប់

មាត្រា១: ផ្ទេរមុខតំណែងលោក **ម៉េង គុននី** ចៅក្រមសាលាដំបូងខេត្តមណ្ឌលគិរី ឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៩៦៦ច.ល

ពរស.១២.១១.២០០៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១២

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៨៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រមលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២

ត្រាស់បង្គាប់

មាត្រា១: ដាក់ឲ្យស្ថិតនៅក្នុងភាពទំនេរដោយគ្មានបៀវត្ស រយពេល០១ឆ្នាំ ចំពោះលោកស្រី **ស្រ៊ុន ឈន់ចលក្ខណ៍** និងលោក **គេច សុម៉ារិទ្ធ** ចៅក្រមសាលាដំបូងខេត្តកណ្តាល ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២ ដល់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៩៦៧ច.ល

ពរស.១២១១.១០០៧

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២

អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រមលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២

ត្រាស់បង្គាប់

មាត្រា១: លុបឈ្មោះលោក **អ៊ីង សារុន** ចៅក្រមសាលាឧទ្ធរណ៍ និងលោក **ត្រី សុខអ៊ី** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចេញពីក្របខណ្ឌអង្គចៅក្រម ដោយមរណភាព ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ:៩៦៨ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
ស៊ុយ សុខា

៣រក. ១២១១.១០០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងឯកឧត្តម **ខៀវ ចំន្ទប៊ុនធឿន** ជាអនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ជំនួសឯកឧត្តម **ម៉ែន ភួន** ដែលត្រូវបានទទួលភារកិច្ចថ្មី។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ:៩៥៨ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុយ សុខា

៣៣៩.១២១១.១០០៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/១១១២/១០០០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីអនុវត្តគម្រោង ចំនួន ០៥រូប ដែលមានស្នាដៃល្អក្នុងការសាងសង់ផ្លូវជាតិ លេខ៨ ពីស្ពានព្រែកតាមាក់ ដល់អន្លង់ជ្រៃ ព្រំដែនកម្ពុជា-វៀតណាម ប្រវែង ១០៩ គ.ម សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

១- ឯកឧត្តម **មាស សឿន**
២- ឯកឧត្តម **នួន ចំរុង**
៣- លោក **ម៉ុន អេង**
៤- លោក **សុខ ស្រ៊ុន**
៥- លោក **គួន ម៉ុនធឿន**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣០៥. ១២១១. ១០១០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១២

លេខៈ ៩៦០ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

ឈុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១២/១០០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/១៩៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ងិន ចិបុល** ជាអនុរដ្ឋលេខាធិការនៃក្រសួងធម្មការ និងសាសនា ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ:៩៥៧ច.ល

ចារទ. ១២១១.១០១១

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ .ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

ស៊យ សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២០៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកាត់ដីទំហំសរុប ៥.៨៥១,៧៤ ហិកតា ចេញពីតំបន់គម្របព្រៃឈើឆ្នាំ ២០០២ ទំហំ ២.៤៧៩,៨៨ ហិកតា និងពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន (គីម ជាធូន គ្រុបខូអិលធីឌី ឆាយណា ហ្គ្រេតខស ខេមបូឌា ហ្វ្រីនឈ័យ ខេមបូឌា លីមីតធីត និងសីលាជាម៉ិច ខូអិលធីឌី) ទំហំ ៣.៣៧១,៨៦ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១៩៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង លើដីទំហំ ៥.៣២៣,២៨ ហិកតា និងដីទំហំ ៥២៨,៤៦ ហិកតា រក្សាបម្រុងទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នៅក្រុងព្រះវិហារ ស្រុករវៀង និងស្រុកគូលែន ខេត្តព្រះវិហារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៤១ គ.គ្រ.ដ.រ.ខ ចុះថ្ងៃទ០១ ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.

ត្រូវបានកាត់ដីទំហំសរុប ៥.៨៥១,៧៤ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ទំហំ ២.៤៧៩,៨៨ ហិកតា និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន (គីម ជាធូន គ្រុបខូអិលធីឌី ឆាយណា ប្រេ្កតខស ខេមបូឌា ហ្រ្គីនឈ័យ ខេមបូឌា លីមីតធីត និងនឹងសីលាដាម៉ិច ខូអិលធីឌី) ទំហំ ៣.៣៧១,៨៦ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង លើដីទំហំ ៥.៣២៣,២៨ ហិកតា និងដីទំហំ ៥២៨,៤៦ ហិកតា រក្សាបម្រុងទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅក្រុងព្រះវិហារ ស្រុករវៀង និងស្រុកគូលែន ខេត្តព្រះវិហារ ដែលមានទំហំ និង ស្ថិតនៅក្នុងភូមិសាស្ត្រដូចខាងក្រោមៈ

- ផ្ទៃដីទំហំសរុប ២.៣៩៦,២៨ ហិកតា នៅភូមិចំការស្រមូវ សង្កាត់ប៉ាហាល ក្រុងព្រះវិហារ ដែលក្នុងនោះប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នូវផ្ទៃដីទំហំ ២.១៧៧,៨២ ហិកតា និងរក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នូវផ្ទៃដីទំហំ ២១៨,៤៦ ហិកតា តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ។
- ផ្ទៃដីទំហំសរុប ១.៤៥៣,៤៦ ហិកតា នៅភូមិអូរតាលោក ឃុំមេទម ស្រុករវៀង ដែលក្នុងនោះប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នូវផ្ទៃដីទំហំ ១.៣២៤,៤៦ ហិកតា និងរក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនូវផ្ទៃដីទំហំ ១២៩ ហិកតា តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ។
- ផ្ទៃដីទំហំសរុប ៧២៣ ហិកតា នៅភូមិម្រេច ឃុំស្រយង់ ស្រុកគូលែន ដែលក្នុងនោះប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នូវផ្ទៃដីទំហំ ៦៥៨ ហិកតា និងរក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នូវផ្ទៃដីទំហំ ៦៥ ហិកតា តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៣) នៃអនុក្រឹត្យនេះ។
- ផ្ទៃដីទំហំសរុប ១.២៧៩ ហិកតា នៅភូមិក្តាក់ ឃុំត្បែងពីរស្រុកគូលែន ដែលក្នុងនោះប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នូវផ្ទៃដីទំហំ ១.១៦៣ ហិកតា និងរក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នូវផ្ទៃដីទំហំ ១១៦ ហិកតា តាមប្រព័ន្ធ

កូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៣) នៃអនុក្រឹត្យនេះ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១.១៩៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅក្រុងព្រះវិហារ ស្រុករវៀង និងស្រុកគូលែន ខេត្តព្រះវិហារ ដែលមានចំនួនគ្រួសារ និងស្ថិតនៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៥៧៩ គ្រួសារ នៅភូមិចំការស្រមូវ សង្កាត់ប៉ាហាល ក្រុងព្រះវិហារ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៣៤៩គ្រួសារ នៅភូមិអូរតាលោក ឃុំរមទម ស្រុករវៀង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៨៨ គ្រួសារ នៅភូមិម្រេច ឃុំស្រយង់ ស្រុកគូលែន
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១៨២ គ្រួសារ នៅភូមិក្លាក់ ឃុំត្បែងពីរ ស្រុកគូលែន

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ពន្ធ(១)

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ២១០.៩៧.....ចុះថ្ងៃទី.១៦...ខែ.១១.ឆ្នាំ២០១២ ស្តីពីការកាត់ដីទំហំសរុប ៥.៨៥១,៧៤ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ទំហំ ២.៤៧៩,៨៨ ហិកតា និងពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន(គីម ជាធូនគ្រុបខូអិលធីឌី ឆាយណាហ្គ្រេតខស ខេមបូឌា ហ្គ្រីនឈ័យ ខេមបូឌា លីមីធីត និងសីលាដាម៉ិច ខូអិលធីឌី) ទំហំ ៣.៣៧១,៨៦ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ១.១៩៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង លើដីទំហំ៥.៣២៣,២៨ ហិកតា និង ទំហំ ៥២៨,៤៦ ហិកតារក្សាបម្រុងទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នៅក្រុងព្រះវិហារ ស្រុករវៀង និង ស្រុកគូលែន ខេត្តព្រះវិហារ



ឧបសម្ព័ន្ធ(២)

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...២.០.៩......ចុះថ្ងៃទី...១៦...ខែ...១១...ឆ្នាំ២០១២ ស្តីពីការកាត់ដីទំហំសរុប ៥.៨៥១,៧៤ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ទំហំ ២.៤៧៩,៨៨ ហិកតា និងពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន(តឹម ជាធូនគ្រុបខូអិលធីឌី ឆាយណាហ្គ្រេតខស ខេមបូឌា ហ្គ្រីនល័យ ខេមបូឌា លីមីធីត និងសីលាដាម៉ិច ខូអិលធីឌី) ទំហំ ៣.៣៧១,៨៦ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១៩៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង លើដីទំហំ៥.៣២៣, ២៨ ហិកតា និង ទំហំ ៥២៨,៤៦ ហិកតារក្សាបម្រុងទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរួមវិន្ត នៅក្រុងព្រះវិហារ ស្រុករវៀង និង ស្រុកគូលែន ខេត្តព្រះវិហារ



ឧបសម្ព័ន្ធ(៣)

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ២៦៩...ចុះថ្ងៃទី១៦...ខែ១១...ឆ្នាំ២០១២ ស្តីពីការកាត់ដីទំហំសរុប ៥.៨៥១,៧៤ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ទំហំ ២.៤៧៩,៨៨ ហិកតា និងពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន(គីម ជាធូនគ្រុបខូអិលធីឌី ឆាយណាហ្វ្រេតខស ខេមបូឌា ហ្វ្រីនឈ័យ ខេមបូឌា លីមីធីត និងសីលាជាម៉ិច ខូអិលធីឌី) ទំហំ ៣.៣៧១,៨៦ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ១.១៩៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង លើដីទំហំ៥.៣២៣,២៨ ហិកតា និង ទំហំ ៥២៨,៤៦ ហិកតារក្សាបម្រុងទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរួមរ័ត្ន នៅក្រុងព្រះវិហារ ស្រុករវៀង និង ស្រុកគូលែន ខេត្តព្រះវិហារ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២១០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩៨៤,៣៨ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ស ម្រេ ច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៩៨៤.៣៨ (ប្រាំបួនរយប៉ែតសិបបួនក្បៀសសាមសិបប្រាំបី) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដើម្បីធ្វើការវិនិយោគដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា លេខ ១២៦០-ចណលថ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ របស់សាលាខេត្តព្រះវិហារ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២១១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩៨០ ហិកតា
ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ស ម្រេ ច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៩៨០ (ប្រាំបួនរយប៉ែតសិប) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដើម្បីធ្វើការវិនិយោគដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា លេខ ១២៥៩-ចណលផ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ របស់សាលាខេត្តព្រះវិហារ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧១៧.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកាត់ដីទំហំសរុប ១៣.៧៦០ ហិកតា ដែលក្នុងនោះកាត់ចេញ ពីតំបន់ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ពីព្រៃសម្បទានឃុំសាគរ ពីដីសម្បទានព្រៃឬស្សី ក្រុមហ៊ុន ភាពីម៉ិក ពីដែនជម្រកសត្វព្រៃភ្នំសំកុស និងពីដីសហគមន៍ព្រៃឈើព្រៃត្រឡាច និងភ្នំរូង ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ១២.៥១៣ ហិកតា សម្រាប់ធ្វើ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.២១៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង និងដីភ្នំទំហំ ១.២៤៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុកវេលវែង និងស្រុកសំឡូត ខេត្តបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១២/១០០៣ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៩៩៨ ខបប ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីទំហំសរុប ១៣.៧៦០ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ទំហំ ២.៦៩៧,៧៧ ហិកតា ពីព្រៃសម្បទានយូរីសាគរ ទំហំ ៨០៩០,១៣ ហិកតា ពីដីសម្បទានព្រៃឫស្សី ក្រុមហ៊ុន ភាពីម៉ិក ទំហំ ២.៨៧៨,៥ ហិកតា ពីដែនជម្រកសត្វព្រៃភ្នំសំកុស ទំហំ ១០០ ហិកតា និងពីដីសហគមន៍ព្រៃឈើព្រៃត្រឡាច និងភ្នំរូង ទំហំ ៤៣,៦០ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ១២.៥១៣ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីភ្នំទំហំ ១.២៤៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុករុក្ខគិរី និងស្រុកសំឡូត ខេត្តបាត់ដំបង ដែលមានទំហំ និងស្ថិតនៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

១ ផ្ទៃដីទំហំសរុប ៤.៧៧២ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋទំហំ ២៦៩៧,៧៧ ហិកតា ពីព្រៃសម្បទានយូរីសាគរទំហំ ២០៨០,៦៣ ហិកតា ពីដីសហគមន៍ព្រៃឈើព្រៃត្រឡាច ទំហំ ៧,៣១ ហិកតា និងពីដីសហគមន៍ព្រៃឈើភ្នំរូង ៣៦,២៩ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៤.២៧៨ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីភ្នំទំហំ ៤៩៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិរូង១ ឃុំព្រៃត្រឡាច ស្រុករុក្ខគិរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ ។

២. ផ្ទៃដីទំហំ ៦.០០៩,៥ ហិកតា កាត់ចេញពីព្រៃសម្បទានយូរីសាគរ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៥.២៥៦,៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីភ្នំទំហំ ៧៥៣ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃធំ ឃុំកំពុងល្ពៅ ស្រុកសំឡូត តាមប្រព័ន្ធ កូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ ។

៣.ផ្ទៃដីទំហំ ២.៩៧៨.៥ ហិកតា ដែលក្នុងនោះកាត់ចេញពីដីសម្បទានព្រៃឫស្សី ក្រុមហ៊ុនភាពីម៉ិច ទំហំ ២.៨៧៨,៥ ហិកតា និងពីដែនជម្រកសត្វព្រៃភ្នំសំកុស ទំហំ ១០០ ហិកតា តាមរយៈព្រះរាជក្រឹត្យកាត់ចេញពីព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ភូមិស្ទឹងតូច ឃុំកំពុងល្ពៅ ស្រុកសំឡូត តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២.២១៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែង នៅស្រុករុក្ខគិរី និងស្រុកសំឡូត ខេត្តបាត់ដំបង ដែលមានចំនួនគ្រួសារ និងស្ថិតនៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៨៦២ គ្រួសារ នៅភូមិរូង១ ឃុំព្រៃត្រឡាច ស្រុករុក្ខគិរី
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១.០៩៧ គ្រួសារ នៅភូមិព្រៃធំ ឃុំកំពុងល្ពៅ ស្រុកសំឡូត
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ២៥៦ គ្រួសារ នៅភូមិ ស្ទឹងតូច ឃុំកំពុងល្ពៅ ស្រុកសំឡូត

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្ដែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធ(១) នៃអនុក្រឹត្យលេខ ១១៧៧ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ស្តីពីការកាត់ដីទំហំសរុប ១៣.៧៦០ ហិកតា ដែលស្ថិតនៅក្នុងតំបន់ព្រៃឈើបម្រុងទុកអភិរក្សរបស់រដ្ឋ ពីព្រៃសហគមន៍ ពីដីសម្បទានព្រៃឈើ ក្រុមហ៊ុន ពីដែនជម្រកសត្វព្រៃភ្នំសំកុស និងពីដីសហគមន៍ព្រៃឈើ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋចំនួនផ្ទៃដី ទំហំ ១២.៥១៣ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.២១៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងរស់នៅជាក់ស្តែង និងដីភ្នំទំហំ ១.២៤៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុករុក្ខគីរី និងស្រុកសំឡូត ខេត្តបាត់ដំបង



ប្រព័ន្ធកូអរដោនេ :
តំបន់ទី : 48N
ចំណោលផែនទី : UTM
ទិន្នន័យយោង : WGS1984

ប្រភពទិន្នន័យ:
ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ
គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២





ចំនុចនិយាមការ		
ល.រ	X	Y
1	330693	1394526
2	330805	1392999
3	330373	1388721
4	329972	1387799
5	328745	1387798
6	328142	1387131
7	328562	1386884
8	330362	1385299
9	329718	1383326
10	327718	1382089
11	326695	1383487
12	326159	1383704
13	326087	1385686
14	326760	1386769
15	326303	1387052
16	326580	1387472
17	324866	1387861
18	323345	1388125
19	323359	1388933
20	324094	1389332
21	324386	1390729
22	326467	1392101
23	327534	1391522
24	327898	1392350
25	327189	1392993
26	330510	1394532

